សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្នកដទៃ ។

www.hoksavann.org

ថ្ងៃទី១២ មិថុនា ២០១១



ពុទ្ធភាសិតថា ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្នកដទៃនេះមានជំរៅណាស់ គឺឈ្នះសេចក្តីអាក្រក់ ដោយការពុំធ្វើអំពើអាក្រក់ អប់រំចិត្តឲ្យបានស្អាតបរិសុទ្ធ ។ ចិត្តបរិសុទ្ធ គឺចិត្តស្ងប់ពុំធ្វើអំពើបាបគ្រប់យ៉ាង មានការបៀតបៀនអ្នកដទៃជាដើម ។ ស្របនឹងពុទ្ធភាសិតមួយទៀតថា ការចង់បានសុខខ្លួនឯង ទៅបៀតបៀនអ្នកដទៃ ពុំបានសុខឡើយ ។ អ្នកប្រព្រឹត្តសុចរិតដោយកាយវាចាចិត្ត ឈ្មោះថាជាអ្នកឈ្នះ, អ្នកប្រព្រឹត្តទុច្ចរិត ឈ្មោះថាជាអ្នកចាញ់ ព្រោះអំពើទុច្ចរិតនោះនឹងផ្តល់សេចក្តីទុក្ខមកដល់ខ្លួន ។ អ្នកខ្លះយល់ថា បើអប់រំចិត្តឲ្យល្អបរិសុទ្ធ ទុកជាអ្នកទន់ខ្សោយ ជាអ្នកចាញ់គេ តាមពិតវិញ បើចិត្តបរិសុទ្ធរមែងមានចិត្តសុខស្ងប់ ហើយពុំមានផលនៃអំពើអាក្រក់ណាមួយឲ្យផលជាទុក្ខឡើយ ។ ផ្ទុយទៅវិញ បើចិត្តពុំបរិសុទ្ធរមែងធ្វើអំពើបាប ហើយផលនៃអំពើបាបនោះ តែផ្តល់ផលជាទុក្ខដល់ខ្លួន ជាពិសេសបើប្រព្រឹត្តអាក្រក់ទៅលើជនណាម្នាក់ មុខជាមានប្រតិកម្មតបវិញក្នុងពេលភ្លាម ឬក្នុងពេលណាមួយដែលឱកាសហុចឲ្យ ដោយផលនៃអំពើបាបដែលខ្លួនប្រព្រឹត្តទៅលើគេ ។ ដូច្នេះជំនះខ្លួនឯងជាជំនះប្រសើរ ព្រោះពុំមានពៀរវេរាជាមួយអ្នកដទៃ ចំណែកជំនះក្រៅពីនោះ ដូចជាជំនះដោយលេងល្បែងភ្នាល់ផ្សេងៗ ជំនះដោយការវិវាទធម្មតាក្តី ថ្នាក់ជាតិក្តី បើជំនះនោះប្រកបដោយការឈ្លានពានផង ជំនះនោះនឹងត្រឡប់ចាញ់វិញ ។

ជំនះខ្លួនឯងដោយការពុំធ្វើអំពើបាបនេះ ពុំមែនជំរុញមិនឲ្យការពារទឹកដី ការពារឯករាជ្យរបស់ខ្លួនឡើយ ផ្ទុយទៅវិញ ភាពនៃចិត្តបរិសុទ្ធនេះនាំឲ្យមានវិចារណញ្ញាណដ៏ខ្ពស់ ជំរុញឲ្យរក្សាការពារអត្តសញ្ញាណជាតិនិងកម្មសិទ្ធិគ្រប់យ៉ាងរបស់ជាតិ មានទឹកដីជាដើមដោយការប្រុងប្រយ័ត្ន ។ តាមព្រឹត្តិការណ៍សាកលលោករហូតមកទល់ពេលនេះ អ្នកប្រព្រឹត្តអាក្រក់រំលោភសិទ្ធិមនុស្ស ត្រូវបានទទួលទោសទណ្ឌកម្មនៅទីបំផុត ។ ហេតុដែលនាំឲ្យមនុស្សសាងអាក្រក់ មកអំពីគំនិតយល់ខុសថា អំពើរបស់ខ្លួននោះ អាចផ្តល់សេចក្តីសុខឲ្យដល់ខ្លួន ។ នេះជាការយល់ផ្ទុយអំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺព្រះអង្គសំដែងថា អំពើអាក្រក់តែងផ្តល់ផលជាទុក្ខ ពុំមែនផ្តល់ផលជាសុខឡើយ ។ មួយទៀត ការកើតវិវាទនឹងគ្នាមកអំពីការយល់ផ្ទុយគ្នា រហូតបង្កើតអំពើហឹង្សាដើម្បីការពារគំនិតខ្លួន រហូតរកមធ្យោបាយធ្វើឲ្យគេវិនាសទៀតផង ។ តាមព្រះពុទ្ធសាសនាក៏ដូចគ្នានឹងរបបប្រជាធិបតេយ្យ ការបញ្ចេញយោបល់ស្របក្តីផ្ទុយពីមតិខ្លួនក្តី តែងតែគោរពសិទ្ធិបញ្ចេញយោបល់ទាំងនោះ ។ មុននឹងឈ្នះអ្នកដទៃ មនុស្សត្រូវឈ្នះខ្លួនឯងជាមុន ។ ឈ្នះខ្លួនឯងគឺការពុំធ្វើអំពើបាប ជាពិសេសពុំបៀតបៀនអ្នកដទៃ ។ ការមិនបៀតបៀននេះហើយ ជាស្ពានមុខនាំឲ្យបន្ថយសត្រូវ ចំរើនមិត្ត សម្បូណ៌មិត្តរាប់អានគ្នា ដោយសេចក្តីល្អរបស់ខ្លួន ។ ជនសប្បុរសដែលតែងតែប្រព្រឹត្តធ្វើអំពើល្អនេះ មិនថាតែមនុស្សទេដែលយកជាមិត្ត សូម្បីសត្វតិរច្ឆានក៏ចូលមកជិតយកជាមិត្តដែរ គឺបើមនុស្សមិនបៀតបៀនវា វាមិនមានការភិតភ័យ តែងចូលមកជិតសំដែងការស្រឡាញ់រាប់អាន ។ បានសេចក្តីមកថា ជនសប្បុរសស្ងប់នូវអំពើបាប លោករស់នៅទីណា តែងតែធ្វើឲ្យជនដែលរស់នៅទីនោះបានសេចក្តីសុខ ដោយបង្ហាញនូវមាគ៌ាដែលនាំឲ្យបានសេចក្តីសុខចំរើន ។

ចំពោះព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធនោះ គឺដោយព្រះអង្គឈ្នះខ្លួនព្រះអង្គឯង ។ តើព្រះពុទ្ធឈ្នះនូវអ្វី គឺឈ្នះនូវមារ មានកិលេសមារជាដើម ។ យោលតាមពុទ្ធប្រវត្តិ ព្រះសិទ្ធត្ថពោធិសត្វ មុននឹងបានត្រាស់ជាព្រះពុទ្ធ ព្រះអង្គបានផ្ចាញ់មារពីរប្រភេទគឺ មារមួយប្រភេទប្រើសង្គ្រាមក្តៅ គឺមារាធិរាជព្រមទាំងបរិវារជាច្រើនពាន់ មានអាវុធគ្រប់ដៃ ចូលប្រយុទ្ធវាយប្រហារចំពោះព្រះបរមពោធិសត្វ ដែលគង់ក្រោមដើមពោធិព្រឹក្សដោយព្រះទ័យស្ងប់ក្នុងសមាធិ ។ ព្រះអង្គផ្សាយធម៌តបមារវិញ ដោយធម៌មេត្តានិងបារមីទាំង១០ដែលព្រះអង្គបានកសាង មារក៏ត្រូវបរាជ័យ ។ មារប្រភេទទីពីរ គឺបានប្រើសង្គ្រាមត្រជាក់ គឺរមារាធិរាជប្រើបុត្រីរបស់ខ្លួន ដែលមានរូបរាងកាយស្អាតបាត មកប្រលោមលួងលោមព្រះពោធិសត្វដោយផ្លូវកាមគុណ ពេលនោះមារត្រូវបរាជ័យទៀត ដោយព្រះពោធិសត្វមានស្មារតីរឹងមាំក្នុងផ្លូវសមថវិបស្សនា ។ មារប្រភេទក្តៅបានដល់ទោសៈ មារប្រភេទត្រជាក់បានដល់លោភៈ ឬរាគៈ ។ បន្ទាប់ពីមារត្រូវបរាជ័យហើយ ព្រះពោធិសត្វព្រះសិទ្ធត្ថក៏បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ឈ្មោះថាព្រះអង្គឈ្នះខ្លួនឯងហើយ ។

យោលតាមពុទ្ធភាសិត ឈ្នះខ្លួនប្រសើរជាងឈ្នះអ្នកដទៃ បានជាមេរៀនសំរាប់សង្គមកម្ពុជា ដោយខ្មែរគ្រប់ឋានៈគប្បីរួបរួមគ្នា រក្សាការពារជាតិ ការពារទឹកដី ការពារឯករាជ្យរបស់ខ្លួនឲ្យគង់វង់ក្នុងស្មារតីជាតិឲ្យបានរឹងមាំ ជាពិសេសអ្នកកាន់អំណាចខ្មែរបច្ចុប្បន្នត្រូវធ្វើខ្លួនឲ្យឈ្នះខ្លួនឯង ពោលគឺកុំសាងអាក្រក់ ធ្វើឲ្យពលរដ្ឋខ្លួនមានទុក្ខក្តៅក្រហាយ បញ្ហាដីធ្លីត្រូវដោះស្រាយឲ្យមានសមធម៌ ត្រូវគោរពការបញ្ចេញមតិរបស់ពលរដ្ឋដោយសេរី ដូចការធ្វើកូដកម្មបាតុកម្មជាដើម ដោយមិនត្រូវបង្ក្រាប តែត្រូវរក្សាសន្តិសុខឲ្យពលរដ្ឋក្នុងការធ្វើកូដកម្មបាតុកម្មនេះ ។ គប្បីធ្វើអន្តរាគមន៍ជួយខ្មែរកម្ពុជាក្រោមនៅប្រទេសវៀតណាមដែលត្រូវវៀតណាមធ្វើបាប ហើយផ្តល់អត្តសញ្ញាណប័ណ្ណឲ្យខ្មែរកម្ពុជាក្រោម ដែលមករស់នៅប្រទេសកម្ពុជាដោយគ្មានលក្ខខណ្ឌ ។៚